## សិលាចារឹកព្រះស្រីសៅគន្ធកុដិ

នៅក្បែរស្ពានបុរាណមួយដែលមានឈ្មោះថា "ស្ពានពងទឹក" ស្ថិតនៅក្នុងស្រុកពួក ខេត្តសៀមរាប[១] គេបានប្រទះឃើញថ្មមួយផ្ទាំងរាងជាសន្ទឹកសីមា មានអក្សរចារឹកខ្លីចំនួនពីរបន្ទាត់ ដែលមិនទាន់ចុះក្នុងបញ្ជីសារពើភណ្ឌសិលាចារឹកនៃប្រទេសកម្ពុជានៅឡើយ។ នៅផ្នែកម្ខាងមានចារឹកអក្សរបុរាណថា "**ព្រះឝ្រីឝៅគន្ធកុដិ**" បើសរសេរជាអក្សរទំនើបគឺ "**ព្រះស្រីសៅគន្ធកុដិ**"។ **សៅគន្ធកុដិ** ជាសំណេរតាមពាក្យសំស្ក្រឹតដែលត្រូវនឹងសំណេរពាក្យបាលីថា **សុគន្ធកុដិ**។ នៅផ្នែកម្ខាងទៀតមានឆ្លាក់រូបចេតិយ ដែលខឿននៃរូបចេតិយនោះមានទម្រង់ជាឈូកផ្កាប់ឈូកផ្ងារ ហើយផ្នែកកណ្ដាលដែលជាអង្គចេតិយមានរាងជាកណ្ដឹង។ នៅផ្នែកកំពូលនៃរូបចេតិយមានធ្វើជា "**ដំបែ**" សម្រាប់ទ្រផ្នែកខាងលើដែលគេហៅថា "**ត្រយ៉ូង**"។

សិលាចារឹកនេះពុំមានកាលបរិច្ឆេទទេ ប៉ុន្តែតាមតួអក្សរ យើងអាចសន្និដ្ឋានបានថាស្ថិតនៅក្នុងស.វ.ទី១៤។ ក្នុងរាជ្យព្រះបាទស្រិន្ទ្រវម៌្ម (១២៩៥-១៣០៧គ.ស) យើងចាប់ផ្ដើមឃើញមានភស្ដុតាងសិលាចារឹកមួយចំនួន បង្ហាញពីវត្តមានព្រះពុទ្ធសាសនាថេរវាទនៅប្រទេសកម្ពុជា។ អ្នកស្រាវជ្រាវចាត់ទុកសិលាចារឹកគោកស្វាយចេក ជាសិលាចារឹកពុទ្ធសាសនាថេរវាទប្រើភាសាបាលីដំបូងគេ។ ចារឹកខ្លីនៅក្បែរស្ពានពងទឹកនេះ ក៏មានសេចក្ដីទាក់ទងនឹងព្រះពុទ្ធសាសនាថេរវាទដែរ ហើយតាមការស្រាវជ្រាវកន្លងមក វាជាភស្ដុតាងដំបូងតែមួយគត់ដែលបង្ហាញពី **សុគន្ធកុដិ** នៅប្រទេសកម្ពុជា។

**សុគន្ធកុដិ** ឬ **គន្ធកុដិ** ជាកុដិដែល **អនាថបណ្ឌិកសេដ្ឋី** សាងថ្វាយព្រះពុទ្ធអង្គនៅវត្តជេតពននាក្រុងសាវត្ថី។ ក្រោយមកកុដិដែលគេសាងថ្វាយព្រះពុទ្ធនៅទីដទៃទៀត ក៏ហៅថា **សុគន្ធកុដិ** ដែរ ដូចជាកុដិដែលនាងវិសាខាសាងថ្វាយនៅបុព្វារាមជាដើម។ **សុគន្ធកុដិ** ឬ **គន្ធកុដិ** មានន័យថាកុដិដែលមានក្លិនក្រអូប ហើយក៏ជាឈ្មោះកុដិដែលជាលំនៅព្រះ

[១] សូមមើល https://cisark.mcfa.gov.kh/core/showsite.php?id=4531&keyword

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង

*សម្មាសម្ពុទ្ធ មានផ្កាក្រអូបដែលគេដាក់បូជា[២] ព្រោះបរិស័ទទាំងឡាយតែងយកផ្កាភ្ញី និងគ្រឿងក្រអូបជាដើមថ្វាយព្រះពុទ្ធនៅខាងមុខកុដិនោះ នៅពេលពួកគេមកថ្វាយបង្គំព្រះអង្គ។ នាពេលបច្ចុប្បន្ននេះ ពុទ្ធសាសនិកគ្រប់ទិសទីដែលធ្វើធម្មយាត្រាទៅកាន់ទីតាំងវត្តជេតពន នៅតែមានទំនៀមបូជាផ្កានៅសុគន្ធកុដិដដែល។*

*សម្រាប់ការសិក្សាបែបបុរាណវិទ្យាលើទំនាក់ទំនងថ្មចារឹកនេះ និងទីតាំងនៅជុំវិញ គឺពុំទាន់ឃើញមានការសិក្សានៅឡើយទេ ដូច្នេះទើបយើងមិនទាន់យល់ច្បាស់អំពីតួនាទីរបស់ថ្មរាងសន្ទឹកសីមានេះ ថាតើមានតួនាទីជាអ្វីឱ្យពិតប្រាកដ?។ ចំណែកឯរូបចេតិយដែលឆ្លាក់នៅលើថ្មនោះ ទំនងជាឧទ្ទិសជាព្រះស្រីសៅគន្ធកុដិ(?) ឬពុំនោះសោតថ្មគោលចារឹកនេះអាចយកមកពីទីតាំង ព្រះស្រីសៅគន្ធកុដិ ដែលគេសាងក្នុងអំឡុងស.វ.ទី១៤ នោះ។*

*នៅប្រទេសកម្ពុជានាអំឡុងប្រមាណជាពីរទសវត្សរ៍ចុងក្រោយនេះ យើងសង្កេតឃើញមានការចាប់ផ្ដើម និងនិយមសាងសង់អគារកុដិ ឬចេតិយ នៅក្នុងអារាមឬអាស្រមមួយចំនួនដែលឱ្យឈ្មោះស្រដៀងៗគ្នាថា* ***គន្ធកុដិ ព្រះគន្ធកុដិ ព្រះមហាគន្ធកុដិ សុគន្ធកុដិ*** *ឬ* ***ព្រះមហាសុគន្ធកុដិ*** *ជាដើម។ ឈ្មោះទាំងនេះក៏បានប្រើសម្រាប់ដាក់ជាឈ្មោះវត្តឬអាស្រមពុទ្ធសាសនាមួយចំនួនផងដែរ។*

---

[២] *វចនានុក្រមខ្មែរ ភាគ២* (១៩៦៨) ទំព័រ១៣៦៩។

*អត្ថបទដោយ៖ លោក ហ៊ិន ឈុនតេង*



គោលចារឹកមានពាក្យ «ព្រះគ្រីគៅគន្ធកុដិ»



រូបចម្លាក់ចេតិយ



សុគន្ធកុដិ វត្តឧណ្ណាលោម

អត្ថបទដោយ៖ លោក ហ៊ិន ឈុនតេង